គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកឃ្លាំមើលមូលដ្ឋាន

*ភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១*

នេះជាលើកទីពីរហើយដែល **ខុមហ្វ្រែល** បានរៀបចំធ្វើការវាយតម្លៃ ដើម្បីផ្តល់រង្វាន់សំរាប់អ្នកឃ្លាំមើលមូលដ្ឋានរបស់ខ្លួន (លើកទី១ ក្នុងឆ្នាំ២០០៩)។ ដំណើរការនៃការងារនេះចំណាយរយៈពេលជាងមួយខែ គឺចាប់ផ្តើមពីពាក់កណ្តាលខែតុលា រហូតដល់ចុងខែវិច្ឆិកា ឆ្នាំ២០១០។ ការវាយតម្លៃបានរកឃើញអ្នកឃ្លាំមើលមូលដ្ឋានចំនួន ០៥ រូប ជាប់ចំណាត់ថ្នាក់ពី លេខ១ ដល់លេខ៣ និងពីនាក់ទៀតបានទទួលរង្វាន់លួងចិត្ត។ ពួកគេត្រូវបានជ្រើសរើសចេញពីបេក្ខជនចំនួន ២៩ រូប មកពី ១៣ ខេត្ត ដែលបានដាក់ពាក្យសុំធ្វើការប្រកួតប្រជែង។ ក្រុមការងារវាយតម្លៃរបស់ខុមហ្វ្រែលមួយក្រុម បានចុះធ្វើការងារនេះដល់មូលដ្ឋានដើម្បីធ្វើការសំភាសន៍ផ្ទាល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឃុំរបស់ពួកគេ។

អ្នកឃ្លាំមើលមូលដ្ឋានទាំង ៥ រូប នេះ គឺជាបណ្តាញរបស់ខុមហ្វ្រែលនៅថ្នាក់មូលដ្ឋានដែលបានចូលរួមស្ម័គ្រចិត្តក្នុងការងារសង្កេតឃ្លាំមើលក្រុមប្រឹក្សាមូលដ្ឋាន។ ពួកគេបានចូលរួមបង្កើតការទំនាក់ទំនង ឬវេទិកាពិភាក្សារវាងប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ពួកគេត្រូវបានវាយតម្លៃឲ្យជាប់ចំណាត់ថ្នាក់ឆ្នើម លើការបំពេញកិច្ចការមូលដ្ឋាននៅក្នុងឃុំ/សង្កាត់របស់ពួកគេផ្ទាល់សំរាប់ឆ្នាំ២០០៩-២០១០។ ក្រៅពីកិច្ចការខាងលើ ពួកគេក៏បានផ្តួចផ្តើមគំនិតជួយធ្វើអន្តរាគមន៍ ធ្វើរបាយការណ៍ និងជាអ្នកទំនាក់ទំនងនាំព័ត៌មានពីប្រជាពលរដ្ឋទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ហើយពីក្រុមប្រឹក្សាឃុំ/សង្កាត់ទៅប្រជាពលរដ្ឋវិញ និងកិច្ចការផ្សេងទៀតដែលបំរើឲ្យផលប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងឃុំ/សង្កាត់របស់ខ្លួន។

ឆ្លងតាមការខិតខំបំពេញការងារយ៉ាងសកម្មរបស់ក្រុមការងារ និងគណៈកម្មការវាយតម្លៃលើការបំពេញកិច្ចការមូលដ្ឋាន ជាលទ្ធផលទទួលបាន ៖

»**ចំណាត់ថ្នាក់លេខ ១** ៖ បានទៅលើលោក **សាំង ប៊ុនធឿន** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពីឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃអន្តរាគមន៍លើបញ្ហាទំនាស់ផ្លូវ និងប័ណ្ណអ្នកក្រីក្រដែលកើតមានក្នុងឃុំ ដើម្បីឲ្យក្រុមប្រឹក្សាឃុំជួយដោះស្រាយ។



»**ចំណាត់ថ្នាក់លេខ ២** ៖ បានទៅលើលោក **អ៊ុក សូត** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពីឃុំបរយ៉ាខា ស្រុកប៉ៃលិន ខេត្តប៉ៃលិន មានស្នាដៃលើការអប់រំប្រជាពលរដ្ឋចូលរួមធ្វើផែនការអភិវឌ្ឍន៍ឃុំ។



»**ចំណាត់ថ្នាក់លេខ ៣** ៖ បានទៅលើលោក **ប៉េ សុផល** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពីឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមានស្នាដៃចូលរួមក្នុងការដាក់លូបណ្តោះទឹកពីផ្លូវលិចទឹក។



**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
**P.O. Box** 1145, Phone : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

»**ខ្ទង់ល្អចចិត្ត** បានទៅលើលោកស្រី **តាំង ពុទ្ធិ** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពីឃុំកំពង់គរ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ លោកស្រីបានចូលរួមគៀងគរប្រជាពលរដ្ឋឲ្យចូលរួមប្រជុំនៅផ្ទះរបស់គាត់ ដើម្បីលើកសំណើ បញ្ហា កង្វល់ តម្រូវការ ដាក់ជូនក្រុមប្រឹក្សាឃុំឲ្យបានដឹង និងរកដំណោះស្រាយ។

»**ខ្ទង់ល្អចចិត្ត**មួយទៀតបានទៅលើលោក **ខ្លឹម មើល** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពីឃុំសុខដុម ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី លោកបានចូលរួមលើកសំណើទៅប្រធានភូមិ ដើម្បីប្រជុំក្រុមប្រឹក្សាឃុំ លើបញ្ហាដីកប់ខ្មោចជនជាតិនៅមូលដ្ឋាន។

កម្មវិធីផ្តល់រង្វាន់នេះបានប្រព្រឹត្តទៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង ៣.៤៥ នាទី នៅទីស្នាក់ការកណ្តាលខុមហ្វ្រែល ដែល មានការអញ្ជើញចូលរួមពីលោក **គល់ បញ្ញា** នាយកប្រតិបត្តិ គណៈកម្មាធិការប្រតិបត្តិ គណៈកម្មាការវាយតម្លៃ និងលេខាខេត្តខុមហ្វ្រែលទាំង ២៣ ផងដែរ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាព័ត៌មានដល់សាធារណៈជនបានជ្រាប៕



**បេសកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព( ការទទួលខុសត្រូវ )របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។